# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២០៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលសរសេរជាអក្សរកាត់ថា**គ.ក.ប.** ដើម្បីដឹកនាំការងារសម្របសម្រួលពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា សំដៅជំរុញនិងធានានូវការអនុវត្តគោលនយោបាយជាតិកម្មសិទ្ធិបញ្ញា ពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីសិក្សា ផ្សព្វផ្សាយ អនុវត្តច្បាប់ និងបទប្បញ្ញត្តិកម្មសិទ្ធិបញ្ញានានាឱ្យមានប្រសិទ្ធភាព និងអនុលោមតាមការសន្យារបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិនានាជាមួយអង្គការពាណិជ្ជកម្មពិភពលោក អង្គការសហប្រជាជាតិ អង្គការអន្តរជាតិនានា និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី តំបន់និងពហុភាគី រួមទាំងសហការទទួលនិងប្រើប្រាស់ជំនួយបច្ចេកទេស ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីអង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍនានាឱ្យមានប្រសិទ្ធភាពខ្ពស់។

# ជំពូកទី២
# សមាសភាព តួនាទី និងភារកិច្ចនៃគ.ក.ប.

**មាត្រា២ .-**

គ.ក.ប. មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| - តំណាងក្រសួងបរិស្ថាន១រូប | សមាជិក |
| - តំណាងក្រសួងព័ត៌មាន១រូប | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌១រូប | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល១រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍១រូប | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី១រូប | សមាជិក |
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគ.ក.ប. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

គ.ក.ប. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគីឬពហុភាគី លើវិស័យកម្មសិទ្ធិបញ្ញា ជាមួយបណ្តាប្រទេស អង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងការអនុវត្តគម្រោងនិងប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា
- សហការជំរុញការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានិងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ព្រមទាំងការអនុវត្តកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិនានា
- សហការជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាព ដើម្បីការពារទប់ស្កាត់និងលុបបំបាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងការរំលោភបំពានសិទ្ធិជាក់លាក់ដែលពាក់ព័ន្ធផ្សេងទៀត ដែលរួមទាំងធនធានសេនេទិក-ពន្ធុ ចំណេះដឹងជាប្រពៃណី ការសម្តែង វប្បធម៌ប្រពៃណី ក្រោមប្រព័ន្ធច្បាប់ដោយឡែក
- សហការជំរុញការអនុវត្តពិធីសារណាហ្គូយ៉ាស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក-ពន្ធុ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក-ពន្ធុដោយស្មើភាព និងសមធម៌នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
- សហការសិក្សាស្រាវជ្រាវនិងវាយតម្លៃអំពីផលប្រយោជន៍ និងផលប៉ះពាល់នៃកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិនានាដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា

- សហការរៀបចំនិងជំរុញការអនុវត្តគោលនយោបាយជាតិកម្មសិទ្ធិបញ្ញា និងផែនការសកម្មភាពការងាររបស់**គ.ក.ប.**
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិផ្នែកកម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ចំណេះដឹងដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការ អ្នកបណ្តុះបណ្តាល អ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យកម្មសិទ្ធិបញ្ញា ទាំងក្នុងវិស័យឯកជនក៏ដូចជាសាធារណជន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំបញ្ចូលមុខវិជ្ជាកម្មសិទ្ធិបញ្ញាចូលក្នុងកម្មវិធីសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជននានា ការបោះពុម្ពឯកសារបណ្តុះបណ្តាលនិងឯកសារស្រាវជ្រាវផ្សេងៗពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនប្រចាំឆ្នាំ ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## ការប្រព្រឹត្តទៅនៃគ.ក.ប.

**មាត្រា៤ .-**

**គ.ក.ប.** ត្រូវធ្វើការប្រជុំយ៉ាងតិច១(មួយ)ដងក្នុង១(មួយ)ឆ្នាំ។

សមាសភាព**គ.ក.ប.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាមួយ ដឹកនាំការប្រជុំជំនួសបាន។

របៀបរបបនៃការប្រជុំរបស់គ.ក.ប. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

ក្នុងករណីចាំបាច់ គ.ក.ប. អាចអញ្ជើញបុគ្គលដែលមានជំនាញឬតំណាងក្រសួង ស្ថាប័នដែលពាក់ព័ន្ធក្រៅពីសមាជិកផ្តល់សេចក្តីបំភ្លឺឬចូលរួមក្នុងកិច្ចប្រជុំ។

**មាត្រា៥ .-**

**គ.ក.ប.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ប្រធាន
- មន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងមាត្រា២ អនុប្រធាននិងសមាជិក។

លេខាធិការដ្ឋានគ.ក.ប. មានទីតាំងស្ថិតនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម និងមានសិទ្ធិប្រើមន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញាតាមការចាំបាច់។

សមាសភាព តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃ**គ.ក.ប.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគ.ក.ប.។

**មាត្រា៦ .-**

**គ.ក.ប.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៤
## ប្រភពធនធាននិងការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា៧ .-**

**គ.ក.ប.** មានធនធានសម្រាប់អនុវត្តសកម្មភាពការងារដោយថវិកាជាតិ នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម។

**គ.ក.ប.** មានសិទ្ធិទទួលនិងគ្រប់គ្រងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន មូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា៨ .-**

រាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការតែងតាំងនិងការបង្កើតយន្តការនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មសិទ្ធិបញ្ញា ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

អនុក្រឹត្យលេខ១៤២ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញានិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ